ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក

ស

វ

**Work Activities**

ប្រចាំខែកញ្ញា ឆ្នាំ២០១៨



# មាតិកា


| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|
| I- | កិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | |
| | - សេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម | ១-២ |
| II- | សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| | - កិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាមួយក្រុមការងារRIA របស់ក្រសួងអប់រំ យុវជន និងកីឡា | ៣ |
| III- | កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១៨ | ៤-១៣ |
| IV- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៨ | ១៤-១៥ |

# សេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី
## ពាណិជ្ជកម្មតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម



ផ្អែកលើចំណារដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ លើសំណើរបស់ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរៀបចំកិច្ចប្រជុំនៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ឃឹម ណុលសន** និង ឯកឧត្តម **ឌុយ ឆៅ** អនុប្រធាន ECOSOCC ឯកឧត្តម **អ៊ុច ថោងសេង** និង ឯកឧត្តម **ទេស អៃតជា** សមាជិក ECOSOCC ព្រមទាំងមន្ត្រីលេខាធិការដ្ឋាន ECOSOCC ផងដែរ។

កិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម លើកទី១៦ ដែលប្រារព្ធធ្វើនៅថ្ងៃទី១៦-១៧ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងហាណូយប្រទេសវៀតណាម បានប្រគល់ភារកិច្ចជូនក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម ពិភាក្សាស្វែងរកការឯកភាពរួមលើសេចក្តីព្រាងស្តីពី "ពាណិជ្ជកម្មតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម"។ ដើម្បីពន្លឿនកិច្ចការនេះ និងស្វែងរកធាតុចូល ក្រសួងពាណិជ្ជកម្មបានស្នើសុំ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ចាត់មន្ត្រីជំនាញ ដើម្បីពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ។

សេចក្តីព្រាងស្តីពី"ពាណិជ្ជកម្មតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម" មានគោលបំណងដូចខាងក្រោមនេះ ៖

-ពង្រឹងមិត្តភាព សហប្រតិបត្តិការទូលំទូលាយគ្រប់ជ្រុងជ្រោយ ការអភិវឌ្ឍដោយចីរភាព

-ជំរុញពាណិជ្ជកម្មទំនិញនិងសេវាកម្មឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ

-បង្កើតទំនាក់ទំនងរយៈពេលវែង ប្រកបដោយនិរន្តរភាព និងស្ថេរភាព

-សម្រួលការងារអន្តោប្រវេសន៍ មធ្យោបាយ ការនាំចូល ការនាំចេញ ពាណិជ្ជកម្ម ការដោះដូរទំនិញរវាងប្រទេសទាំងពីរ៕

# កិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាមួយក្រុមការងារ RIA របស់ក្រសួងអប់រំ យុវជន និងកីឡា



ឯកឧត្តម **សេង រត្នមុនី** អគ្គលេខាធិការរង និងជាប្រធានផ្នែកបណ្តុះបណ្តាលនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំកិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាមួយក្រុមការងារ RIA របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយ លោក **ពៅ ទី** អនុប្រធាននាយកដ្ឋាននីតិកម្ម ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃ សំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានអប់រំ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ។



បញ្ហាចម្បងដែលនាំឲ្យមានការគិតគូរពីសំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានអប់រំ គឺ៖

១.គ្មានមូលដ្ឋានច្បាស់លាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធការអប់រំ

២.ពុំមានអ្នកទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានច្បាស់លាស់

៣.ភាពមិនច្បាស់លាស់ពីព័ត៌មានដែលត្រូវផ្សព្វផ្សាយ និងព័ត៌មានដែលមិនត្រូវផ្សព្វផ្សាយ

៤.ការផ្សព្វផ្សាយអំពីព័ត៌មានអប់រំដល់សាធារណជនពុំសូវទូលំទូលាយ ឬនៅមានកម្រិត

៥.ប្រសិទ្ធភាពនៃការផ្សព្វផ្សាយព័ត៌មានអប់រំប្រែប្រួលតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ

កិច្ចប្រជុំបានដំណើរការទៅដោយរលូន ដែលមានលោក **ពៅ ទី** អនុប្រធាននាយកដ្ឋាន បានធ្វើបទបង្ហាញអំពីខ្លឹមសារនៃរបាយការវាយតម្លៃលើផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានអប់រំ ជូនអង្គប្រជុំយ៉ាងក្បោះក្បាយ។ អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍យ៉ាងយកចិត្តទុកដាក់ និងបានផ្តល់មតិយោបល់ ដើម្បីកែលម្អលើចំណុចខ្វះខាតបន្តិចបន្តួច ក្នុងន័យធ្វើឲ្យរបាយការណ៍កាន់តែមានតម្លៃ។

## II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA)

# កិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាមួយ ក្រុមការងារ RIA របស់ក្រសួងអប់រំ យុវជន និងកីឡា



ឯកឧត្តម **អេង រត្នមុនី** អគ្គលេខាធិការរង និងជាប្រធានផ្នែកបណ្តុះបណ្តាលនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំកិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាមួយក្រុមការងារ RIA របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយ លោក **ពៅ ទី** អនុប្រធាននាយកដ្ឋាននីតិកម្ម ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃ សំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានអប់រំ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ។



បញ្ហាចម្បងដែលនាំឲ្យមានការគិតគូរពីសំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានអប់រំ គឺៈ

១.គ្មានមូលដ្ឋានច្បាស់លាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធការអប់រំ

២.ពុំមានអ្នកទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានច្បាស់លាស់

៣.ភាពមិនច្បាស់លាស់ពីព័ត៌មានដែលត្រូវផ្សព្វផ្សាយ និងព័ត៌មានដែលមិនត្រូវផ្សព្វផ្សាយ

៤.ការផ្សព្វផ្សាយអំពីព័ត៌មានអប់រំដល់សាធារណជនពុំសូវទូលំទូលាយ ឬនៅមានកម្រិត

៥.ប្រសិទ្ធភាពនៃការផ្សព្វផ្សាយព័ត៌មានអប់រំប្រែប្រួលតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ

កិច្ចប្រជុំបានដំណើរការទៅដោយរលូន ដែលមានលោក **ពៅ ទី** អនុប្រធាននាយកដ្ឋាន បានធ្វើបទបង្ហាញអំពីខ្លឹមសារនៃរបាយការវាយតម្លៃលើផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានអប់រំ ជូនអង្គប្រជុំយ៉ាងក្បោះក្បាយ។ អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍យ៉ាងយកចិត្តទុកដាក់ និងបានផ្តល់មតិយោបល់ ដើម្បីកែលម្អលើចំណុចខ្វះខាតបន្តិចបន្តួច ក្នុងន័យធ្វើឲ្យរបាយការណ៍កាន់តែមានតម្លៃ។

# III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១៨



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែសីហា ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហា ឆ្នាំ២០១៨សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៧% ធៀបនឹងខែមុន និងកើនឡើង២,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៥,៤% | ឧស្ម័ន: | +៦,៣% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,៥% | ប្រេងសាំង: | +៦,០% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,៣% | ប្រេងម៉ាស៊ូត: | +៥,៤% |
| ម្ហូបអាហារ: | +២,៧% | ត្រីស្រស់: | +៤,៧% |
| ការដឹកជញ្ជូន: | +២,៥% | សាច់ជ្រូក: សាច់ | +៣,០% |
| សុខាភិបាល: | +១,៥% | គោ: | +២,៦% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +១,២% | សាច់មាន់: | +១,៨% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | +០,៩% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៦–២០១៨

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា P | តុលា P | វិច្ឆិកា P | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ២,៧% | ២,៦% | | |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៥% | ០,៣% | ០,១% | -០,៣% | ០,៧% | ០,៣% | ០% | ០,១% | | |
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | ០,៤% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |

P: តួលេខខែកញ្ញា តុលា និងវិច្ឆិកា ឆ្នាំ២០១៨ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តារាង




## ១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | *សីហា* ២០១៨ | *កក្កដា* ២០១៨ | *សីហា* ២០១៧ | *ប្រភេទ* | *សីហា* ២០១៨ | *កក្កដា* ២០១៨ | *សីហា* ២០១៧ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៨៤៛/១$ | ៤០៥៩៛/១$ | ៤០៥០៛/១$ | **បាត/ដុល្លារ** | ៣២,៧៨បាត/១$ | ៣៣,២៦បាត/១$ | ៣៣,២១បាត/១$ |
| **៛/បាត** | ១២៥៛/១បាត | ១២២៛/១បាត | ១២២៛/១បាត | **ដុង/ដុល្លារ** | ២៣២៨៤ដុង/១$ | ២៣២៣៨ដុង/១$ | ២២៦៩៨ដុង/១$ |
| **៛/ដុង** | ០,១៧៥៛/១ដុង | ០,១៧៥៛/១ដុង | ០,១៧៨៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែសីហា ឆ្នាំ ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៦៩៦,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤២៤,២ លានដុល្លារ ( *មធ្យមប្រចាំខែ ១០៧,៣% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៦៧៣,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៤១៨,៤ លានដុល្លារ ( *មធ្យមប្រចាំខែ ១០៨% នៃផែនការ*) និងចំណូលមូលធនចំនួន ២២,៨ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង ១៣,២%និងកើនឡើង២១,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៦-២០១៨
(ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៤៩៩ប៊ីលានរៀលកើនឡើង២២,៨% ធៀបនឹងខែមុននិង កើនឡើង៣៥,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៧៤,៩ប៊ីលានរៀលថយចុះ៣២,៧% ធៀបនឹងខែមុន និងថយចុះ ៣៦,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :+១០,១% | (+៣១,៦%) | ➢អាជ្ញាបណ្ណក្នុងស្រុក : កើនគំហុក | (+៩៨១%) |
| (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | | ➢ នេសាទ:+៨៣៣% | (-៦៦,៧%) |
| ➢ ចំណូលពន្ធដារ: +៨,៩% | (+១១,៦%) | ➢សម្បទានរ៉ែ: +៥៦,៣% | (+១០៣,២%) |
| (អគ្គនាយកដ្ឋានពន្ធដារ) | | ➢ អាកាសចរណ៍ស៊ីវិល: +៣៧,៨% | (+២៣,១%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១៦០៨,៦ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤០២,២ លានដុល្លារ (*មធ្យមប្រចាំខែ ៨១% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១២៣៧,៨ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨៥% នៃផែនការ*) និងចំណាយមូលធនមានចំនួន៣៧០,៨ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ១៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៨,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ១៤,២% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៧,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៨៨,១ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២២,០៣លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៦-២០១៨
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែសីហា ឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ$M_2$ មានចំនួន៨២១០៤ប៊ីលានរៀល កើនឡើង៥,១% ធៀបនឹងខែមុន និងកើនឡើង ២០,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ១,៧% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ៦,៥% និងប្រាក់បញ្ញើជារូបិយ-បណ្ណ៥,៧%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែសីហា ឆ្នាំ២០១៨




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៥% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៥% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៨

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៨% | ១៦,៧% | ១៥,៥% | ១៥,៣% | ១៥,៣% | ១៥,៤% | ១៦% | ១៥,៥% | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៦% | ១១,៥% | ១១,៣% | ១១,៤% | ១១,៩% | ១០,៨% | ១១,៣% | ១០,៩% | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែសីហា ២០១៨: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




---

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៩០៦៤លានដុល្លារ កើនឡើង០,៩៣%ធៀបនឹងខែមុន និង កើនឡើង១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២៨៦៩៧ ប៊ីលានរៀលកើនឡើង ៦,៨%ធៀបនឹងខែមុន និងកើនឡើង១៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *សីហា២០១៨* | *កក្កដា២០១៨* | *សីហា២០១៧* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៧៧៧៤១ | ៧៥២២៩ | ៦៤០៥៨ |
| ក្នុងនោះ ជារៀល | | ២៥៤០ | ១១២៨ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៩៥០១ | ១៥៧៧៩ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,០៧% | ៦,០៦% | ៥,៩៩% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៥% | ៤,៤៤% | ៤,៤២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,២៨% | ១១,៣៧% | ១៤,៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១០,៤៨% | ១១,១២% | ១១,៧៩% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៨,០% | ១៨% | ១៨% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៧,៩% | ១៨% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,៥% | ១៦,៦% | ១៧,២% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែសីហា ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៧៩,៨៨ពាន់តោន កើនឡើង៥%ធៀបនឹងខែមុននិងកើនឡើង៦,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៨០៧,៥GWHមានការកើនឡើង០,៨%ធៀបនឹងខែមុន និងកើនឡើង១៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៦៤២,៧GWHមានការកើនឡើង២,៨% ធៀបនឹងខែមុន និងកើនឡើង៣៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១១០,៦៦GWHមានការថយចុះ៨,៣% ធៀបនឹងខែមុន និងមានការ ថយចុះ៣៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន៤៦,៨២GWHមានការ ថយចុះ១,៥% ធៀបនឹងខែមុន និងមានការថយចុះ៩,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន៧,៣៣GWHមានការថយចុះ០,៨% ធៀបនឹងខែមុន និងមានការថយចុះ១០,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៨២៣,៦លានដុល្លា កើនឡើង១២%ធៀបនឹងខែមុននិង កើនឡើង១៧,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន—សីហា២០១៨* | *ចំនួន—កក្កដា២០១៨* | *ចំនួន—សីហា២០១៧* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ២៦ | ១៦ | ២៥ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦៣៨ | ១៦១២ | ១៦៥៥ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | ៧ | ១២ | ១៩ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១១ | ៦ | ១០០ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន១៨៣៤,៤ពាន់ម² មានការថយចុះ៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៨៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៩១៥,៣លានដុល្លារមានការកើនឡើង៩%ធៀបនឹងខែមុន និងកើនឡើង៤២៤%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម² — សីហា២០១៨* | *ពាន់ម² —កក្កដា២០១៨* | *ពាន់ម² —សីហា២០១៧* |
|---|---|---|---|
| ▪ លំនៅឋាន | ៤៦៧,៧ | ៧៥៤,១ | ៤៣៨,០ |
| ▪ ឧស្សាហកម្ម | ២៦៨,៤ | ១៣៤,៦ | ៣២,៩ |
| ▪ពាណិជ្ជកម្ម | ១០១៨,៧ | ៧៣១,៨ | ១០៥,៧ |
| ▪ ទេសចរណ៍ | ៥៤,១ | ៣៦៩,៩ | ៦៣,៦ |
| ▪ផ្សេងៗ | ០,៣ | ០,២ | ០,២ |
| អនុញ្ញាតសរុប | ១៨៣៤,៤ | ១៩៩១,៥ | ៦៤៥,៦ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺពាណិជ្ជកម្ម៥៥,៥% និងលំនៅឋាន២៥,៥% នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់– សីហា ២០១៨ | នាក់–កក្កដា ២០១៨ | នាក់–សីហា ២០១៧ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ១៣៤៨ | ១២៥២ | ១២៩៧ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៧៧៣៤ | ១៦២៣៧ | ១៣៦១៦ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១០២៤១ | ៩៣១៣ | ៨៩៨០ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៧៤៩៣ | ៦៩២៤ | ៤៦៣៦ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | សីហា២០១៨ | កក្កដា២០១៨ | សីហា២០១៧ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៧៥៧,៩ | ៦១,៣ | ៦៤,១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣២,០ | ០,០ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១០៧,២ (៥៨,០) | ៦១,៣ (២៣,១) | ៦៤,១ (១០,៥) |
| វិស័យទេសចរណ៍ | ៦៨,៣ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៥៥០,៤ | ០,០ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២០ | ១៥ | ១៧ |
| បង្កើតការងារ (ពាន់នាក់) | ៣៧,០ | ៩,៦ | ១៣,១ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន–សីហា២០១៨ | ចំនួន–កក្កដា២០១៨ | ចំនួន–សីហា២០១៧ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១១៥៩ | ១១៨៥ | ៤៥៥ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៣ | ១០ | ៧ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៧៦៧ | ៧១០ | ៥១៩ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៧៣០,១ពាន់តោនថយចុះ១៤,១% ធៀបនឹងខែមុន និង ថយចុះ១២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-៦,៤% | (+១០,១%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-០,៨% | (-៤៩,៦%) |
| ▪ កំពង់ផែកំពង់សោម:-១៥,០% | (-១៧,៧%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៥៣,៩% | (-៥១,៤%) |

## ➢ ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២១,០ | +២៣,៦% | +១១,១% |
| ក្នុងនោះទទួល | ២,៦ | -៣,៨% | -២,៩% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១០៧,៣ | +១៩,៥% | +៤,៥% |
| ក្នុងនោះទទួល | ៦៣,២ | +២០,១% | +១២,៨% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៨៨៧,២ | +២,១% | -២៣,៣% |
| ក្នុងនោះហៅចូល | ៥៨៣,១ | +៥,៤% | -២០,១% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៧៥៦៨,០ | -១០,៧% | -៣៥,៧% |
| ក្នុងនោះហៅចូល | ៧៤៨៣,១ | -១០,១% | -៣៦,១% |

## ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៤,៦ | +១៩,៧% | -៧,១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៥៣,៦ | +២០,២% | +៥,៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៧៩០,២ | +១២,៥% | +២១,១% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៩១,៤ | +២៨,៩% | +១៧,៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤៩៤,០ | +៨,៨% | +១៥,៦% |
| ✓ តាមផ្លូវអាកាស | ៣៤៩,០ | +១៣,១% | +២៧,០% |
| ✓ តាមផ្លូវគោក និងទឹក | ១៤៥,០ | -០,២% | -៤,៨% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែសីហា ឆ្នាំ២០១៨ មានចំនួន ៥៨៨៦,៦ប៊ីលានរៀល (ស្មើនឹង១៤៧១,៦លានដុល្លារ ស.រ.អា.) កើនឡើង៨,៧% ធៀបនឹងខែមុននិង កើនឡើង៣៤,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៣,១% | +៨,៦% | រថយន្តសរុប (បី.ល.រ) | +៣៨,៣% | +៤៣,៣% |
| ប្រេងម៉ាស៊ូត | +២,២% | -១៤,៨% | រថយន្តសរុប (គ្រឿង) | +៣៧,៣% | +១៥,១% |
| ឧស្ម័ន | -១៥,៦% | +១៣,៦% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១៣,៦% | -៦,៣% |
| អគ្គិសនីនាំចូលដោយ | -១,៥% | -៩,៥% | ម៉ូតូ (គ្រឿង) | +១៦,២% | +៨,៨% |
| ដែកសំណង់ | -២,៣% | +៤៤,៣% | អង្ករ | +៥៤,៧% | +៤៧២,៨% |
| ស៊ីម៉ង់ត៍ | -១,៥% | -៥,០% | ផ្លែឈើនិងបន្លែ | +១០,១% | -៩,១% |
| គ្រឿងអេឡិចត្រូនិក | -៩០,៨% | | ជីនិងថ្នាំកសិកម្ម | -១៦,២% | +៧,០% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | +៤,៧% | +១១,៦% |

➡ **ការនាំចេញ** ខែសីហា ឆ្នាំ២០១៨ មានចំនួន**៥៥៦០,២**ប៊ីលានរៀល ស្មើនឹង**១៣៩០**លានដុល្លារ ស.រ.អា. (**៩៤**% នៃការនាំចូល)កើនឡើង១៥,៨%ធៀបនឹងខែមុន និងកើនឡើង២៣,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -២៣,៣% | -៩១,៤% | ផលិតផលនេសាទ | កើនគំហុក | -៣១,៨% |
| វាយនភណ្ឌនិងស្បែកជើង | +១៥,៣% | +៣៣,៤% | កៅស៊ូ | +៤០,៧% | +០,៩% |
| អង្ករ | +១០៣,៨% | +១៨,៥% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហា ឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃឧស្ម័ន | ០,៣% | +៦,៣% | |
| ២ | ថ្លៃប្រេងសាំង | -០,១% | +៦,០% | |
| ៣ | ថ្លៃប្រេងម៉ាស៊ូត | ០,១% | +៥,៤% | |
| ៤ | អាករលើតម្លៃបន្ថែម | -៧,៧% | -២០,៦% | |

## ៧) សេចក្តីសន្និដ្ឋាន

១) ក្នុងខែសីហាឆ្នាំ ២០១៨ ថ្លៃទំនិញប្រើប្រាស់បានកើនឡើងជាមធ្យម ០,៧% ធៀបនឹងខែមុន ជាអត្រាខ្ពស់ជាងគេ ចាប់តាំងពីខែមករាមក បើប្រៀបធៀបនឹងខែដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានកំណើនប្រក្រតី គឺ ២,៦% ។ បច្ចុប្បន្ន ដោយអត្រាប្តូរប្រាក់មានស្ថិរភាព ថ្លៃប្រេងឥន្ធនៈគឺជាកត្តាចម្បងមួយនៃបម្រែបម្រួលថ្លៃទំនិញ។ ដូច្នេះអត្រាអតិផរណាឆ្នាំ២០១៨ អាស្រ័យលើបម្រែបម្រួលថ្លៃប្រេងឥន្ធនៈនាខែបន្តបន្ទាប់រហូតដល់ចុងឆ្នាំ។

២) កម្ពុជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងវិស័យសុខាភិបាល ប៉ុន្តែយោងតាមស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន បរិមាណនិងគុណភាពនៃសេវាសុខាភិបាល ទាំងមធ្យោបាយសម្ភារៈនិងធនធានមនុស្ស មិនទាន់ឆ្លើយតបបានតាមតម្រូវការ ដែលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ មានភស្តុតាងមួយចំនួនបង្ហាញតាម ការត្អូញត្អែរពីសំណាក់ប្រជាពលរដ្ឋអំពី គុណភាពសេវា ក្រមសីលធម៌មន្ត្រីសុខាភិបាល និងការចាកចេញទៅស្វែងរកសេវាពិនិត្យព្យាបាល នៅប្រទេសជិតខាង ដោយចំណាយប្រាក់យ៉ាងច្រើនទៅបម្រើសកម្មភាពសេដ្ឋកិច្ចទីនោះ។

៣) ដោយស្ថានការណ៍ប្រែប្រួលឆាប់រហ័ស គោចិញ្ចឹមនៅកម្ពុជាមានការថយចុះគួរឲ្យកត់សម្គាល់ ទាំងសម្រាប់ជាមធ្យោបាយអូសទាញ ទាំងសម្រាប់កាប់យកសាច់។ ការនេះធ្វើឲ្យទីផ្សារសាច់គោមានអសមតុល្យរវាងតម្រូវការនិងការផ្គត់ផ្គង់ ឯថ្លៃសាច់គោឡើងថ្លៃខ្លាំង។ បច្ចុប្បន្នកម្ពុជាកំពុងមានតម្រូវការនាំគោចូលពីបរទេស ជាពិសេសពីអូស្ត្រាលី ជាគោពូជ ឬគោស្ទាវយកមកបំប៉នដើម្បីកាប់សាច់។ មានការលើកឡើងជាសំណូមពរក្នុងអង្គប្រជុំថា គួរកុំយកពន្ធលើការនាំចូលគោពូជ (មេនិងបា)៕



រូបភាពនៃកិច្ចប្រជុំស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា



## IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៩/១៨ ម៉ោង១៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរកីឡាករ កីឡាការិនីកម្ពុជា ជ័យលាភីមេដាយមាស ក្នុងការប្រកួតកីឡាអាស៊ីលើកទី១៨ "The 18th Asian Games" នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ០៤/០៩/១៨ ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី "ពាណិជ្ជកម្មតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម" នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៩/០៩/១៨ ម៉ោង០៨:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសំណេះសំណាលរបស់ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** អបអរសាទរមិទ្ទិញខួបអនុស្សាវរីយ៍គម្រប់១០ឆ្នាំ ថ្ងៃបង្កើតបញ្ជាការដ្ឋានអង្គរក្ស និងសម្ពោធដាក់ឲ្យប្រើប្រាស់សមិទ្ធផលនានាក្នុងបញ្ជាការដ្ឋានអង្គរក្ស នៅទីបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស (ទួលក្រសាំង-តាខ្មៅ ខេត្តកណ្តាល)។ |
| ៤ | ០៩/០៩/១៨ ម៉ោង១៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពិសាបាយសាមគ្គីអបអរសាទរខួបអនុស្សាវរីយ៍គម្រប់១០ឆ្នាំ ថ្ងៃបង្កើតបញ្ជាការដ្ឋានអង្គរក្ស នៅទីបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស (ទួលក្រសាំង-តាខ្មៅ ខេត្តកណ្តាល)។ |
| ៥ | ១០/០៩/១៨ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១១/០៩/១៨ ម៉ោង០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **យឹម ណុលសន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១២/០៩/១៨ ម៉ោង០៩:៣០នាទី | បន្តដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១៤/០៩/១៨<br>**ម៉ោង១៦:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **កែវ រ៉េមី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៧/០៩/១៨<br>**ម៉ោង០៩:៣០នាទី** | ចូលរួមប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្សព្វផ្សាយ៖<br>១-អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨។<br>២-សេចក្តីសម្រេចលេខ ២១ សសរ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៨/០៩/១៨<br>**ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែកក្កដា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៩/០៩/១៨<br>**ម៉ោង០៦:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិស្វាយទាប ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ |
| ១២ | ២១/០៩/១៨<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ២៥/០៩/១៨<br>**ម៉ោង១១:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុខដារ៉ានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in